**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា១ ._**

ត្រូវបានបង្កើតសាកលវិទ្យាល័យមួយឈ្មោះថា **សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ** The University of Heng Samrin Thbongkhmum សរសេរកាត់ជាអក្សរខ្មែរថា ស.ហ.ស.ត. និងជាអក្សរឡាតាំងថា UHST ដែលស្ថិតនៅក្នុងភូមិនិគមលើ(តំបន់ចម្ការម៉ៃសាក់) ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២ ._**

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ ._**

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ មានភារកិច្ចបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ។ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាល ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេច។

**មាត្រា៤ ._**

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ មានមហាវិទ្យាល័យចំនួនបី និងវិទ្យាស្ថានបី៖

១- **មហាវិទ្យាល័យកសិកម្ម** មានបួនដេប៉ាតឺម៉ង់គឺ៖
- ដេប៉ាតឺម៉ង់ក្សេត្រសាស្ត្រ : មុខជំនាញក្សេត្រសាស្ត្រ
- ដេប៉ាតឺម៉ង់សេដ្ឋកិច្ចកសិកម្ម : មុខជំនាញសេដ្ឋកិច្ចកសិកម្ម
- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសត្វ : មុខជំនាញវិទ្យាសាស្ត្រសត្វ
- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រព្រៃឈើនិងធនធានធម្មជាតិ : មុខជំនាញវិទ្យាសាស្ត្រព្រៃឈើនិងធនធានធម្មជាតិ

២- **មហាវិទ្យាល័យវិស្វកម្ម** មានបួនដេប៉ាតឺម៉ង់គឺ៖
- ដេប៉ាតឺម៉ង់វិស្វកម្មសំណង់ស៊ីវិល : មុខជំនាញវិស្វកម្មសំណង់ស៊ីវិល
- ដេប៉ាតឺម៉ង់វិស្វកម្មកសិកម្ម : មុខជំនាញគ្រឿងយន្តកសិកម្ម
- ដេប៉ាតឺម៉ង់វិស្វកម្មមេកានិកនិងឧស្សាហកម្ម : មុខជំនាញវិស្វកម្មមេកានិកនិងឧស្សាហកម្ម
- ដេប៉ាតឺម៉ង់វិស្វកម្មគីមីចំណីអាហារ : មុខជំនាញវិស្វកម្មគីមីចំណីអាហារ

៣- **មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ** មានបីដេប៉ាតឺម៉ង់៖
- ដេប៉ាតឺម៉ង់អក្សរសាស្ត្រខ្មែរ : មុខជំនាញអក្សរសាស្ត្រខ្មែរ
- ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា : មុខជំនាញប្រវត្តិវិទ្យា
- ដេប៉ាតឺម៉ង់ទស្សនវិជ្ជា : មុខជំនាញទស្សនវិជ្ជា

៤- **វិទ្យាស្ថានភាសាបរទេស** មានបីដេប៉ាតឺម៉ង់៖
- ដេប៉ាតឺម៉ង់ភាសាអង់គ្លេស : មុខជំនាញភាសាអង់គ្លេស

- ដេប៉ាតឺម៉ង់ភាសាចិន : មុខជំនាញភាសាចិន
- ដេប៉ាតឺម៉ង់ភាសាកូរ៉េ : មុខជំនាញភាសាកូរ៉េ

**៥- វិទ្យាស្ថានបច្ចេកវិទ្យាព័ត៌មាន** មានបីដេប៉ាតឺម៉ង់៖

- ដេប៉ាតឺម៉ង់កម្មវិធីកុំព្យូទ័រ : មុខជំនាញកម្មវិធីកុំព្យូទ័រ
- ដេប៉ាតឺម៉ង់បច្ចេកវិទ្យាព័ត៌មានធុរកិច្ច : មុខជំនាញបច្ចេកវិទ្យាព័ត៌មានធុរកិច្ច
- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកុំព្យូទ័រ : មុខជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ

**៦- វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

អង្គការលេខនៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ មានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ទៅអនាគត សាកលវិទ្យាល័យនេះអាចបើកថ្នាក់បណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី និងឯកទេសថ្មី ដោយរៀបចំសំណុំឯកសារបែបបទសុំការពិនិត្យនិងសម្រេចទៅក្រសួងអប់រំ យុវជន និងកីឡា ស្របតាមនីតិវិធីជាធរមាន។

**មាត្រា៥ .-**

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀតរបស់សាកលវិទ្យាល័យ។

**មាត្រា៦ .-**

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ដឹកនាំដោយសាកលវិទ្យាធិការ១រូប តែងតាំងដោយព្រះរាជក្រឹត្យ និងសាកលវិទ្យាធិការរង១រូបទៅ៤(បួន)រូប តែងតាំងដោយអនុក្រឹត្យ។

មហាវិទ្យាល័យនីមួយៗនិងវិទ្យាស្ថាននីមួយៗ ត្រូវដឹកនាំដោយព្រឹទ្ធបុរសឬប្រធាន១រូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាននិងព្រឹទ្ធបុរសរងឬអនុប្រធានចំនួន៤(បួន)រូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសាស្ត្រាចារ្យនិងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈឱ្យបម្រើការនៅក្នុងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ។

**មាត្រា៧ .-**

ការរៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨ .-**

និស្សិតដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យនេះ ហើយទទួលបានជោគជ័យក្នុងការ បញ្ចប់ការសិក្សា ទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវបាន ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ផ្អែកតាមបញ្ជីឈ្មោះនៃការបញ្ចប់ការសិក្សារបស់និស្សិតជាប់ជាស្ថាពរដែលទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......៧៤........អនក្រ.បក ចុះថ្ងៃទី ០៥. ខែ កុម្ភៈ ឆ្នាំ២០១៦**

**ស្ដីពីការបង្កើតសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ**

